# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៦.សសរ

## សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតក្រុមការងារសម្របសម្រួល ការដាក់អោយប្រើប្រាស់ម៉ាស៊ីនស្កេនន័រ សំរាប់ការត្រួតពិនិត្យនៅតាមច្រកព្រំដែនអន្តរជាតិ និង កំពង់ផែអន្តរជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/ រកត/ ០៧០៤/ ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១:** បង្កើតក្រុមការងារសម្របសម្រួលការដាក់អោយប្រើប្រាស់ម៉ាស៊ីនស្កេនន័រ សំរាប់ការត្រួតពិនិត្យនៅតាមច្រកព្រំដែនអន្តរជាតិ និង កំពង់ផែអន្តរជាតិ ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១- ឯកឧត្តម **ហង់ ជួន ណារ៉ុន** | អគ្គលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | ប្រធាន |
| ២- ឯកឧត្តម **ជា ច៊ាន់ដេត** | នាយកខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី និង រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |
| ៣- លោក **ម៉ក់ ពេជ្រឫទ្ធិ** | ប្រធាននាយកដ្ឋានកាំកុងត្រូលនៃក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៤- លោក **សៀង ឈុនឡី** | អនុប្រធានទី១ទីចាត់ការគយ និង រដ្ឋាករនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | សមាជិក |

**ប្រការ២:** ក្រុមការងារនេះមានភារៈកិច្ចដូចតទៅ៖

១- កំណត់ទីតាំងដែលត្រូវដាក់ម៉ាស៊ីនស្កែននំរអចល័ត និង ចល័ត សំរាប់ការត្រួតពិនិត្យនៅតាមច្រកព្រំដែនអន្តរជាតិ និង កំពង់ផែអន្តរជាតិ លើកលែងតែកំពង់ផែក្រុងព្រះសីហនុ ។

២- សម្រួលនីតិវិធីនៃការសម្របសម្រួលរវាងស្ថាប័នពាក់ព័ន្ធ ដែលនៅតាមចំណុចដាក់ម៉ាស៊ីនស្កែននំរ អោយមានភាពរលូន ។

៣- កំណត់ចំនួនម៉ាស៊ីនស្កែននំរ ដែលត្រូវដាក់នៅតាមទីតាំងនីមួយៗ ។

៤- ចរចារជាមួយភាគីចិនក្នុងការកំណត់តម្លៃ និង ទិញម៉ាស៊ីនស្កែននំរ ដោយប្រើប្រាស់ជំនួយឥតសំណង និង ឥណទានសម្បទានរបស់រដ្ឋាភិបាលចិន ជូនដល់រាជរដ្ឋាភិបាលកម្ពុជា ។

៥- ត្រួតពិនិត្យអោយមានប្រសិទ្ធភាព នូវការអនុវត្តន៍ការត្រួតពិនិត្យដោយម៉ាស៊ីនស្កែននំរនៅតាមច្រកព្រំដែនអន្តរជាតិ និង កំពង់ផែអន្តរជាតិ ។

៦- ធ្វើរបាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាលដើម្បីពិនិត្យ និង សម្រេច ។

**ប្រការ៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី/រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និង សាមីខ្លួន ដែលមានចែងក្នុងប្រការមួយ ត្រូវអនុវត្តសេចក្តីសម្រេចនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០០៤*

**ហ៊ុន សែន**

**កន្លែងទទួល:**

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចចែងក្នុងប្រការ ៣
- ឯកសារ- កាលប្បវត្តិ